# អន្តរប្វីរ
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ អ្នកដឹកនាំខ្មែរគួរយកឧត្តមគតិព្រះវេស្សន្តរជាគំរូក្នុងការដឹកនាំប្រទេស ។

website: www.hoksavann.org

ថ្ងៃទី១៣ វិច្ឆិកា ២០០៧



ព្រះវេស្សន្តរជារឿងជាតកទី១០នៃការកសាងទានបារមីនៃព្រះពោធិសត្វដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធនៃព្រះសមណគោត្តម ។ ក្នុងវគ្គមួយនៃផ្ទៃរឿងនិយាយថា ព្រះវេស្សន្តរបានត្រូវប្រជារាស្ត្រដេញចេញពីព្រះនគរតាមរយៈការធ្វើបាតុកម្មមួយដោយប្រឆាំងនឹងព្រះអង្គអំពីការដាក់ទានដំរីដែលប្រជារាស្ត្រយល់ថាជាដំរីមង្គលរបស់ប្រទេសឲ្យដល់ពួកព្រាហ្មណ៍ ។ ក្នុងពេលនោះ ព្រះវេស្សន្តរបានធ្វើតាមសំណូមពររបស់ប្រជារាស្ត្រព្រះអង្គ ។ ការសំរេចព្រះទ័យបែបនេះចាត់ទុកថា ព្រះវេស្សន្តរពោធិសត្វមានឧត្តមគតិដ៏ខ្ពង់ខ្ពស់ណាស់ ក្នុងការគោរពតាមឆន្ទៈរបស់ប្រជារាស្ត្រ ដោយពុំប្រឆាំងនិងមតិរបស់ប្រជារាស្ត្រ សុខចិត្តទៅរស់នៅក្នុងព្រៃគីរីវង្កត ដូចពាក្យដែលព្រះអង្គបានពោលក្នុងកណ្ឌហេមពាន្តសុំអនុញ្ញាតពីប្រជារាស្ត្រថា យើងនឹងទៅតាមផ្លូវរបស់ក្សត្រដែលធ្វើខុស សូមអ្នកទាំងឡាយអត់ទោសបង្អង់ឲ្យយើងមួយយប់មួយថ្ងៃសិនទំរាំយើងឲ្យទានស្រេច ។ ក្នុងព្រះសកម្មភាពដ៏អស្ចារ្យនេះ យើងគួរលើកឡើងវិភាគថា ហេតុអ្វីបានជាពេលនេះ ព្រះអង្គពុំប្រើកម្លាំងទ័ពដើម្បីបង្ក្រាបប្រជារាស្ត្រដែលធ្វើបាតុកម្មដេញព្រះអង្គចេញពីព្រះនគរ ព្រោះពេលនោះព្រះអង្គមានអំណាចគ្រប់គ្រាន់ជាមួយព្រះបាទស្រីសញ្ជ័យជាព្រះបិតា ។ តាមការសង្កេត ធម្មតាព្រះពោធិសត្វតែងតែសាងអំពើជាកុសល តែងជៀសវាងការបៀតបៀនជានិច្ច យ៉ាងណាមិញព្រះពោធិសត្វវេស្សន្តរដោះស្រាយវិបត្តិនេះដោយសន្តិវិធី ព្រោះព្រះអង្គយល់ថា ការបង្ក្រាបដោយធម៌ហឹង្សាពុំបានជោគជ័យឡើយ ផ្ទុយទៅវិញ រឹតតែបន្ថែមកំហឹងរបស់ប្រជារាស្ត្រឲ្យកើតមានកាន់តែខ្លាំងឡើងថែមទៀត ហើយជាអំពើពាលខុសពីលក្ខណៈរបស់គតិបណ្ឌិត

ផង ។ ម្យ៉ាងទៀត ព្រះអង្គពុំចង់ឲ្យប្រជារាស្ត្រមានទុក្ខព្រួយដោយសារតែព្រះអង្គ ។ ដូច្នេះឃើញថា ព្រះវេស្សន្តរបានគោរពឆន្ទៈរបស់ប្រជារាស្ត្រ បានគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ជាភស្តុតាង ព្រះអង្គបានធ្វើតាមឆន្ទៈរបស់ប្រជារាស្ត្រ ព្រមទាំងបានសុំទោសប្រជារាស្ត្រជាសាធារណៈទៀតផង ។

ដំណោះស្រាយរបស់ព្រះវេស្សន្តរ គឺជាដំណោះស្រាយដោយសន្តិវិធីជាមួយប្រជារាស្ត្រព្រះអង្គ ។ អ្នកដឹកនាំខ្មែរបច្ចុប្បន្ននិងទៅអនាគត គួរហាត់រៀនសិក្សាតាមឧត្តមគតិរបស់ព្រះវេស្សន្តរនេះ គឺព្រះអង្គពុំបានធ្វើឲ្យប្រជារាស្ត្រច្បាំងគ្នាដោយសារតែផលប្រ-យោជន៍ ឬកំហឹងផ្ទាល់ខ្លួនព្រះអង្គឡើយ ។ ព្រះអង្គបានចែកដាច់ពីគ្នា រវាងប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍ជាតិ ហើយបានទទួលកំហុសរបស់ព្រះអង្គជាផ្លូវការផង ។ ប្រទេសក្នុងពិភពលោក មានប្រទេសខ្លះមិនប្រើកម្លាំងបង្ក្រាប សុខចិត្តចុះចេញពីតំណែងតាមឆន្ទៈរបស់ប្រជាពលរដ្ឋបាតុករ ដូចជាលោកស៊ូហារតូនៃប្រទេសឥណ្ឌូណេស៊ីជាដើម ។ ព្រះចៅបាវដាយនៃវៀតណាមសុខចិត្តទៅរស់នៅប្រទេសបារាំង រំលាយរបបរាជានិយម តាមសំណើសុំរបស់យុវជនវៀតណាម ។ ផ្ទុយពីប្រទេសកម្ពុជា នៅឆ្នាំ១៩៧០ បានបង្កើតសង្គ្រាម ពឹងបរទេសឲ្យមកសម្លាប់ជាតិឯង ។ នៅឆ្នាំ១៩៩៨ បានបាញ់ប្រជាពលរដ្ឋបាតុករ ដែលទាមទារលទ្ធិប្រជាធិបតេយ្យ ធ្វើឲ្យព្រះសង្ឃនិងយុវជនខ្មែរត្រូវសុគតនិងស្លាប់អស់ជាច្រើន ។៚

❄ ❄

❄